ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ២៧៤៩ មស.សសា

# សេចក្ដីសម្រេច

## ស្ដីពី

## ការធ្វើនិយ័ត និងបន្ថែមក្របខណ្ឌសម្រាប់ការប្រឡងប្រជែងជ្រើសរើសសិស្ស និស្សិត ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួង ស្ថាប័ន ទាំងប្រាំមួយ សម្រាប់ឆ្នាំ២០១៧

## រដ្ឋមន្ត្រី ក្រសួងមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- ចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លើលិខិតលេខ៤៦១១ មស.ក្រខ. ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ
- យោងលិខិតលេខ៤៨៧ មស.ក្រខ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ
- យោងប្រកាសលេខ២១៦២ មស.ប្រក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ យោងសេចក្ដីជូនដំណឹងលេខ២៤៩ មស.សជណ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ
- យោងស្មារតីអង្គប្រជុំអន្តរក្រសួង ស្ថាប័ន នាថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ នៅទីស្ដីការក្រសួងមុខងារសាធារណៈ
- យោងតាមការចាំបាច់ និងសំណូមពរការងារ។


ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៤០១/+៨៥៥-២៣-៨៦៦៤០៥ | គេហទំព័រ : http://www.mcs.gov.kh

## សម្រេច

**ប្រការ ១ ៖** និយ័ត និងបន្ថែមក្របខណ្ឌជូនក្រសួង ស្ថាប័ន ដូចខាងក្រោម៖

### I-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

- បន្ថែមក្របខណ្ឌចំនួន ០៧កន្លែង ដើម្បីជ្រើសរើសបេក្ខជនមានសមត្ថភាពសមស្របឱ្យចូលបម្រើការងារនៅតាមអង្គភាពក្រោមឱវាទរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រួមមាន ១.នាយកដ្ឋានស្តង់ដានិងសុវត្ថិភាពហោះហើរចំនួន ០១កន្លែង ២.នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពអាកាសយានដ្ឋានចំនួន ០១ កន្លែង ៣.នាយកដ្ឋានសន្តិសុខអាកាសចរស៊ីវិល ចំនួន ០៣កន្លែង និង៤.នាយកដ្ឋានអាជ្ញាបណ្ណបុគ្គលិកចំនួន ០២កន្លែង។

### II-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បន្ថែមក្របខណ្ឌចំនួន ១៧កន្លែង ព្រមទាំងនិយ័តក្របខណ្ឌ ០៣កន្លែង ក្នុងនោះពីមន្ទីរប.ទ. ខេត្តស្ទឹងត្រែង ០២កន្លែង និងមន្ទីរប. ទ. ខេត្តត្បូងឃ្មុំ ០១កន្លែង ដើម្បីជ្រើសរើសបេក្ខជនមានសមត្ថភាពសមស្របចំនួន២០នាក់ឱ្យចូលបម្រើការងារនៅតាមអង្គភាពក្រោមឱវាទរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រួមមាន ១.នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលចំនួន ១៤កន្លែង ក្នុងនោះសម្រាប់ជំនាញគ្រប់គ្រងចំនួន ០៣កន្លែង និងជំនាញគណនេយ្យ ហិរញ្ញវត្ថុ ឬ ធនាគារ ១១កន្លែង២.នាយកដ្ឋានគោលនយោបាយទូរគមនាគមន៍ចំនួន ០៣កន្លែង សម្រាប់ជំនាញភាសាអង់គ្លេស និង៣.នាយកដ្ឋានត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍ ០៣កន្លែង សម្រាប់ជំនាញព័ត៌មានវិទ្យា
- និយ័តក្របខណ្ឌដែលនៅសល់ចំនួន ០២កន្លែង ពីលេខាធិការដ្ឋាន ០១កន្លែង និងមហាវិទ្យាល័យបច្ចេកវិទ្យាគមនាគមន៍ ០១កន្លែង នៃវិទ្យាស្ថានជាតិ យកមកបំពេញបន្ថែមនៅនាយកដ្ឋានគោលនយោបាយប្រៃសណីយ៍សម្រាប់ជំនាញនីតិសាស្ត្រ វិញ
- និយ័តក្របខណ្ឌ ០២កន្លែង ពីមហាវិទ្យាល័យអប់រំពីចម្ងាយនៃវិទ្យាស្ថានជាតិ ដែលនៅសល់យកមកបំពេញបន្ថែមនៅនាយកដ្ឋានសន្តិសុខ បច្ចេកវិទ្យាគមនាគមន៍ វិញ
- និយ័តក្របខណ្ឌចំនួន ០២កន្លែង ពីសាលាក្រោយបរិញ្ញាបត្រនៃវិទ្យាស្ថានជាតិ ដែលនៅសល់យកមកបំពេញបន្ថែមនៅលេខាធិការដ្ឋាននៃវិទ្យាស្ថានជាតិ វិញ
- និយ័តក្របខណ្ឌ ០៣កន្លែង ពីមន្ទីរប.ទ.ខេត្តកណ្តាល ០១កន្លែង មន្ទីរប.ទ.ខេត្តសៀមរាប ០១កន្លែង និងមន្ទីរប.ទ. ខេត្តកែប ០១កន្លែង ដែលនៅសល់យកមកបំពេញបន្ថែមនៅមន្ទីរប.ទ. ខេត្តតាកែវ វិញ
- និយ័តក្របខណ្ឌ ០១កន្លែង ដែលមិនមានបេក្ខជនមានសមត្ថភាពសមស្របក្នុងជំនាញព័ត៌មានវិទ្យាយកមកបំពេញបន្ថែមជំនាញគណនេយ្យ ហិរញ្ញវត្ថុ ឬធនាគារ វិញ សម្រាប់មន្ទីរប.ទ. ខេត្តកំពតវិញ
- និយ័តក្របខណ្ឌ ០២កន្លែង ពីមន្ទីរប.ទ. ខេត្តកោះកុង ដែលនៅសល់យកមកបំពេញបន្ថែមនៅមន្ទីរប.ទ. ខេត្តឧត្តរមានជ័យ វិញ
- និយ័តក្របខណ្ឌ ០១កន្លែង ដែលមិនមានបេក្ខជនមានសមត្ថភាពសមស្របក្នុងជំនាញអង់គ្លេសយកមកបំពេញបន្ថែមជំនាញព័ត៌មានវិទ្យា វិញ សម្រាប់មន្ទីរប.ទ. ខេត្តប៉ៃលិន
- បន្ថែមក្របខណ្ឌ ០១កន្លែង ដើម្បីជ្រើសរើសបេក្ខជនមានសមត្ថភាពសមស្របនៅមន្ទីរប.ទ.ខេត្តពោធិ៍សាត់

- និយ័តក្របខណ្ឌ ០២កន្លែង ពីមន្ទីរប.ទ. ខេត្តរតនគិរី ដែលនៅសល់យកមកបំពេញបន្ថែមនៅមន្ទីរប.ទ. ខេត្តកំពង់ធំ វិញ
- និយ័តក្របខណ្ឌ ០១កន្លែង ពីមន្ទីរប.ទ. ខេត្តកំពង់ចាម ដែលនៅសល់យកមកបំពេញបន្ថែមនៅមន្ទីរប.ទ. ខេត្តក្រចេះ និងនិយ័តក្របខណ្ឌ ០១កន្លែង ទៀត ដែលមិនមានបេក្ខជនសមត្ថភាពសមស្របក្នុងជំនាញព័ត៌មានវិទ្យា យកមកបំពេញបន្ថែមជំនាញគណនេយ្យ វិញ សម្រាប់មន្ទីរប.ទ. ខេត្តក្រចេះ
- និយ័តក្របខណ្ឌ ០៣កន្លែង ពីមន្ទីរប.ទ. ខេត្តមណ្ឌលគិរី ០២កន្លែង និងមន្ទីរប.ទ. ខេត្តស្វាយរៀង ០១កន្លែង ដែលនៅសល់យកមកបំពេញបន្ថែមនៅមន្ទីរប.ទ.ខេត្តកំពង់ឆ្នាំង វិញ
- និយ័តក្របខណ្ឌ ០១កន្លែង ដែលមិនមានបេក្ខជនមានសមត្ថភាពសមស្របក្នុងជំនាញព័ត៌មានវិទ្យា យកមកបំពេញបន្ថែមជំនាញគណនេយ្យ ហិរញ្ញវត្ថុ ឬធនាគារ វិញ សម្រាប់មន្ទីរប.ទ. ខេត្តព្រៃវែង
- និយ័តក្របខណ្ឌ ០១កន្លែង ពីមន្ទីរប.ទ. ខេត្តកំពង់ស្ពឺ ដែលនៅសល់យកមកបំពេញបន្ថែមនៅមន្ទីរប.ទ. ខេត្តពោធិ៍សាត់វិញ
- និយ័តក្របខណ្ឌ ០១កន្លែង ដែលមិនមានបេក្ខជនមានសមត្ថភាពសមស្របក្នុងជំនាញព័ត៌មានវិទ្យា យកមកបំពេញបន្ថែមជំនាញគណនេយ្យ ហិរញ្ញវត្ថុ ឬធនាគារ វិញ សម្រាប់មន្ទីរប.ទ. ខេត្តបាត់ដំបង។

## III-ក្រសួងធនធានទឹក និងឧតុនិយម

- បន្ថែមក្របខណ្ឌចំនួន ២៦កន្លែង ដើម្បីជ្រើសរើសបេក្ខជនមានសមត្ថភាពសមស្របចំនួន ២៦នាក់ ឱ្យចូលបម្រើការងារនៅតាមអង្គភាពក្រោមឱវាទក្រសួងធនធានទឹកនិងឧតុនិយម រួមមាន ១.នាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស ១៤កន្លែង ២.នាយកដ្ឋានផែនការនិងសហប្រតិបត្តិការអន្តរជាតិ ១០កន្លែង និង៣. នាយកដ្ឋានធារាសាស្ត្រកសិកម្ម ០២កន្លែង
- បន្ថែមក្របខណ្ឌចំនួន ០៥កន្លែង ព្រមទាំងនិយ័តក្របខណ្ឌចំនួន ០២កន្លែង ក្នុងនោះពីនាយកដ្ឋានជលសាស្ត្រនិងការងារទន្លេ ០១កន្លែង និងពីនាយកដ្ឋានឧតុនិយម ០១កន្លែង ដើម្បីជ្រើសរើសបេក្ខជនមាន សមត្ថភាពសមស្របចំនួន ០៧នាក់ ឱ្យចូលបម្រើការងារនៅ ១.នាយកដ្ឋានស្វៃកម្ម ០៥កន្លែង ២. នាយកដ្ឋានសហគមន៍កសិករប្រើប្រាស់ទឹក ០២កន្លែង
- បន្ថែមក្របខណ្ឌចំនួន ៣៦កន្លែង ដើម្បីជ្រើសរើសបេក្ខជនមានសមត្ថភាពសមស្របចំនួន ៣៦នាក់ ឱ្យចូលបម្រើការងារនៅថ្នាក់ក្រោមជាតិ រួមមាន ១.មន្ទីរធ.ទ.ឧ. ខេត្តកណ្តាល ០២កន្លែង ២.មន្ទីរធ.ទ.ឧ. ខេត្តកំពត ០៤កន្លែង ៣.មន្ទីរធ.ទ.ឧ. ខេត្តកំពង់ស្ពឺ ០២កន្លែង ៤.មន្ទីរធ.ទ.ឧ.ខេត្តកំពង់ឆ្នាំង ០៤កន្លែង ៥.មន្ទីរធ.ទ.ឧ.ខេត្តកំពង់ធំ ០៣កន្លែង ៦.មន្ទីរធ.ទ.ឧ. ខេត្តកំពង់ចាម ០២កន្លែង ៧.មន្ទីរធ.ទ.ឧ. ខេត្តក្រចេះ ០៣កន្លែង ៨.មន្ទីរធ.ទ.ឧ. ខេត្តរតនគិរី ០១កន្លែង ៩.មន្ទីរធ.ទ.ឧ. ខេត្តបាត់ដំបង ០៤កន្លែង ១០.មន្ទីរធ.ទ.ឧ. ខេត្តកែប ០៤កន្លែង ១១.មន្ទីរធ.ទ.ឧ. ខេត្តព្រៃវែង ០៤កន្លែង និង១២.មន្ទីរធ.ទ.ឧ. ខេត្តតាកែវ ០៣កន្លែង
- និយ័តក្របខណ្ឌដែលនៅសល់ ០១កន្លែង ពីមន្ទីរធ.ទ.ឧ. រាជធានីភ្នំពេញ យកមកបំពេញបន្ថែមនៅមន្ទីរធ.ទ.ឧ ខេត្តព្រះវិហារ វិញ
- និយ័តក្របខណ្ឌដែលនៅសល់ ០៣កន្លែង ក្នុងនោះពីមន្ទីរ.ធ.ទ.ឧ.ខេត្តកោះកុង ០២កន្លែង និងមន្ទីរធ.ទ.ឧ. ខេត្តស្ទឹងត្រែង ០១កន្លែង យកមកបំពេញបន្ថែមនៅមន្ទីរធ.ទ.ឧ. ខេត្តត្បូងឃ្មុំ វិញ។

## IV-ក្រសួងពាណិជ្ជកម្ម

- បន្ថែមក្របខណ្ឌចំនួន ១៧កន្លែង ដើម្បីជ្រើសរើសបេក្ខជនមានសមត្ថភាពសមស្របចំនួន ១៧នាក់ ឱ្យចូលបម្រើការងារនៅទីស្តីការក្រសួងពាណិជ្ជកម្ម រួមមាន ១.នាយកដ្ឋានរដ្ឋបាល ០២កន្លែង ២.នាយកដ្ឋានបុគ្គលិក ០១កន្លែង ៣.នាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក ០១កន្លែង ៤.នាយកដ្ឋានអឺរ៉ុប មជ្ឈិមបូព៌ា និងអាហ្វ្រិក ០១កន្លែង ៥.នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ០២កន្លែង ៦.នាយកដ្ឋានផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់ ០៤កន្លែង ៧.នាយកដ្ឋាននីតិកម្ម ០៣កន្លែង ៨.នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ០១កន្លែង និង ៩.នាយកដ្ឋានកិច្ចការពិព័ណ៌ ០២កន្លែង
- និយ័តក្របខណ្ឌដែលនៅសល់ ០១កន្លែង ពីនាយកដ្ឋានផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់ យកមកបំពេញបន្ថែមនៅអគ្គនាយកដ្ឋានកាំកុងត្រូល ជំនាញព័ត៌មានវិទ្យា
- និយ័តក្របខណ្ឌដែលនៅសល់ ០៦កន្លែង ក្នុងនោះមាន ១.នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ០១កន្លែង ២.នាយកដ្ឋាននាំចេញ នាំចូល ០១កន្លែង និង៣.អគ្គនាយកដ្ឋានកាំកុងត្រូល ជំនាញគីមីចំណីអាហារ ០៣កន្លែងដើម្បីយកមកបំពេញបន្ថែមនៅអគ្គនាយកដ្ឋានកាំកុងត្រូល ជំនាញគ្រប់គ្រងទូទៅសេដ្ឋកិច្ចពាណិជ្ជកម្ម ចំនួន ០៦កន្លែង វិញ
- បន្ថែមក្របខណ្ឌចំនួន ០៤កន្លែង ដើម្បីជ្រើសរើសបេក្ខជនមានសមត្ថភាពសមស្របចំនួន ០៤នាក់ ឱ្យចូលបម្រើការងារនៅមន្ទីរព.ណ. រាជធានីភ្នំពេញ ០៣កន្លែង និងមន្ទីរព.ណ. ខេត្តក្រចេះ ០១កន្លែង
- និយ័តក្របខណ្ឌដែលនៅសល់ចំនួន ០១ កន្លែង ពីមន្ទីរពាណិជ្ជកម្ម ខេត្តកំពង់ធំ យកមកបំពេញបន្ថែមនៅមន្ទីរពាណិជ្ជកម្ម ខេត្តកំពង់ចាម វិញ
- និយ័តក្របខណ្ឌដែលនៅសល់ចំនួន ០២ កន្លែង ក្នុងនោះពីមន្ទីរពាណិជ្ជកម្ម ខេត្តសៀមរាប ០១កន្លែង និងមន្ទីរពាណិជ្ជកម្ម ខេត្តកែប ០១កន្លែង យកមកបំពេញបន្ថែមនៅមន្ទីរពាណិជ្ជកម្ម ខេត្តកំពង់ស្ពឺ វិញ
- និយ័តក្របខណ្ឌដែលនៅសល់ចំនួន ០២ កន្លែង ក្នុងនោះពីមន្ទីរពាណិជ្ជកម្ម ខេត្តមណ្ឌលគិរី ០១កន្លែង និងមន្ទីរពាណិជ្ជកម្ម ខេត្តរតនគិរី ០១កន្លែង យកមកបំពេញបន្ថែមនៅមន្ទីរពាណិជ្ជកម្ម ខេត្តកំពត វិញ
- និយ័តក្របខណ្ឌដែលនៅសល់ចំនួន ០១ កន្លែង ពីមន្ទីរពាណិជ្ជកម្ម ខេត្តស្ទឹងត្រែង យកមកបំពេញបន្ថែមនៅមន្ទីរពាណិជ្ជកម្ម ខេត្តស្វាយរៀង វិញ
- និយ័តក្របខណ្ឌដែលនៅសល់ចំនួន ០១ កន្លែង ពីមន្ទីរពាណិជ្ជកម្ម ខេត្តឧត្តរមានជ័យ យកមកបំពេញបន្ថែមនៅមន្ទីរពាណិជ្ជកម្ម ខេត្តប៉ៃលិន វិញ។

## IV-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- និយ័តក្របខណ្ឌដែលនៅសល់ចំនួន ០៤កន្លែង ពីមន្ទីរកសិកម្ម ខេត្តកណ្តាល ០៣កន្លែង និងមន្ទីរកសិកម្ម ខេត្តតាកែវ ០១ កន្លែង យកមកបំពេញបន្ថែមនៅនាយកដ្ឋានកិច្ចការរដ្ឋបាល វិញ
- និយ័តក្របខណ្ឌដែលនៅសល់ចំនួន ០២កន្លែង ពីនាយកដ្ឋានកសិ.ឧស្សាហកម្ម ០១កន្លែង និងពីមន្ទីរកសិកម្ម.ខេត្តប៉ៃលិន ០១កន្លែង យកមកបំពេញបន្ថែមនៅនាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ វិញ
- និយ័តក្របខណ្ឌដែលនៅសល់ចំនួន ០២កន្លែង ពីរដ្ឋបាលជលផលយកមកបំពេញបន្ថែមនៅនាយកដ្ឋានសវនកម្មផ្ទៃក្នុង ០១កន្លែង និងនាយកដ្ឋានផែនការនិងស្ថិតិ វិញ

- និយ័តក្របខណ្ឌដែលនៅសល់ចំនួន ០៨កន្លែង ពីអគ្គនាយកដ្ឋានកៅស៊ូ ០៥កន្លែង សាលាជាតិកសិកម្មព្រែកលាប ០១កន្លែង និងសាលាជាតិកសិកម្មកំពង់ចាម ០២កន្លែង វិញ
- និយ័តក្របខណ្ឌដែលនៅសល់ចំនួន ០៥កន្លែង ពីរដ្ឋបាលព្រៃឈើ ០៤កន្លែង និងនិយ័តជំនាញនីតិសាស្ត្រ ០១កន្លែងទៀត នៅក្នុងនាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស យកមកបន្ថែមនៅនាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស វិញ
- និយ័តក្របខណ្ឌដែលនៅសល់ចំនួន ០២កន្លែង ពីរដ្ឋបាលជលផល យកមកបំពេញបន្ថែមនៅអគ្គនាយកដ្ឋានកសិកម្ម វិញ
- និយ័តក្របខណ្ឌដែលនៅសល់ចំនួន ០៦កន្លែង ពីមន្ទីរកសិកម្ម.ខេត្តកំពត ០៤កន្លែង និងមន្ទីរកសិកម្ម.ខេត្តកែប ០២កន្លែង មកបំពេញបន្ថែមនៅអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ព្រមទាំងនិយ័តក្របខណ្ឌប្រភេទខ ០១កន្លែង ទៅប្រភេទក្របខណ្ឌក វិញ ក្នុងជំនាញផលិតកម្មនិងបសុ
- និយ័តក្របខណ្ឌដែលនៅសល់ ០១កន្លែង ពីមន្ទីរកសិកម្ម.ខេត្តប៉ៃលិន មកបំពេញបន្ថែមនៅមន្ទីរកសិកម្ម.ខេត្តកំពត ក្នុងជំនាញគណនេយ្យ វិញ
- និយ័តក្របខណ្ឌដែលនៅសល់ ០១កន្លែង ពីរដ្ឋបាលជលផលមកបំពេញបន្ថែមនៅមន្ទីរកសិកម្មខេត្តកែបវិញ
- និយ័តក្របខណ្ឌដែលនៅសល់ ០១កន្លែង ពីជំនាញគីមីវិទ្យា មកជំនាញនីតិសាស្ត្រ សម្រាប់រដ្ឋបាលជលផល
- និយ័តក្របខណ្ឌដែលនៅសល់ ០១កន្លែង ពីជំនាញរៀបចំដែនដី មកជំនាញនីតិសាស្ត្រ សម្រាប់រដ្ឋបាលព្រៃឈើ វិញ
- និយ័តក្របខណ្ឌប្រភេទខ ដែលសល់ ០១កន្លែង ទៅក្របខណ្ឌប្រភេទក ក្នុងជំនាញក្សេត្រសាស្ត្រសម្រាប់អគ្គនាយកដ្ឋានកសិកម្ម
- និយ័តក្របខណ្ឌប្រភេទខ ដែលនៅសល់ ០២កន្លែង ទៅក្នុងក្របខណ្ឌប្រភេទក ពីជំនាញកៅស៊ូមកជំនាញ គណនេយ្យ សម្រាប់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
- និយ័តក្របខណ្ឌដែលនៅសល់ ០២កន្លែង ពីមន្ទីរកសិកម្ម.ខេត្តកោះកុង មកបំពេញបន្ថែមនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម ០១កន្លែង និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ០១កន្លែង វិញ
- និយ័តក្របខណ្ឌដែលនៅសល់ ០៣កន្លែង ពីមន្ទីរកសិកម្ម.ខេត្តកោះកុង ០២កន្លែង និងមន្ទីរកសិកម្ម.ខេត្តបន្ទាយមានជ័យ ០១កន្លែង មកបំពេញបន្ថែមនៅមន្ទីរកសិកម្ម.រាជធានីភ្នំពេញ វិញ
- និយ័តក្របខណ្ឌដែលនៅសល់ ០៤កន្លែង ពីមន្ទីរកសិកម្ម.ខេត្តបន្ទាយមានជ័យ ០១កន្លែង និងមន្ទីរកសិម្ម.ខេត្តឧត្តរមានជ័យ ០២កន្លែង និងមន្ទីរកសិកម្ម.ខេត្តប៉ៃលិន ០១កន្លែង មកបំពេញបន្ថែមនៅមន្ទីរកសិកម្ម.ខេត្តតាកែវ ០៤កន្លែង វិញ
- និយ័តក្របខណ្ឌដែលនៅសល់ ០២កន្លែង ពីកសិកម្ម.ខេត្តកែបមកបំពេញបន្ថែមមន្ទីរកសិកម្ម.ខេត្តព្រះសីហនុ
- និយ័តក្របខណ្ឌ ០១កន្លែង ពីក្របខណ្ឌប្រភេទខ ទៅក្នុងក្របខណ្ឌប្រភេទក ក្នុងជំនាញផលិតកម្មនិងបសុសម្រាប់មន្ទីរកសិកម្ម.ខេត្តកែប
- និយ័តជំនាញ ០១កន្លែង ពីវិស្វកម្មកសិកម្ម ទៅផលិតកម្មនិងបសុ សម្រាប់មន្ទីរកសិកម្ម.ខេត្តព្រះសីហនុ
- និយ័តជំនាញ ០១កន្លែង ពីវិស្វកម្មកសិកម្ម ទៅជំនាញគណនេយ្យ សម្រាប់មន្ទីរកសិកម្ម.ខេត្តត្បូងឃ្មុំ
- និយ័តជំនាញ ០១កន្លែង ពីវិស្វកម្មកសិកម្ម ទៅជំនាញក្សេត្រសាស្ត្រ សម្រាប់មន្ទីរកសិកម្ម.ខេត្តក្រចេះ

- និយ័តជំនាញ ០២កន្លែង ពីជំនាញកសិឧស្សាហកម្ម ០១កន្លែង ជំនាញវិស្វកម្មកសិកម្ម ០១កន្លែងនិងនិយ័តក្របខណ្ឌ ០១កន្លែង ពីក្របខណ្ឌប្រភេទខ ទៅក្របខណ្ឌប្រភេទក ក្នុងជំនាញផលិតកម្មនិងបសុសម្រាប់មន្ទីរកសិកម្ម. ខេត្តកំពង់ឆ្នាំង
- និយ័តជំនាញ ០១កន្លែង ពីរុក្ខកម្ម ទៅផលិតកម្មនិងបសុ សម្រាប់មន្ទីរកសិកម្ម.ខេត្តពោធិ៍សាត់។

VI-**ក្រសួងទេសចរណ៍**

- បន្ថែមក្របខណ្ឌចំនួន ០៨កន្លែង ដើម្បីជ្រើសរើសបេក្ខជនមានសមត្ថភាពសមស្របចំនួន ០៨ នាក់ ឱ្យចូលបម្រើការងារនៅទីស្តីការក្រសួងទេសចរណ៍
- និយ័តក្របខណ្ឌដែលនៅសល់ ០១កន្លែង ពីមន្ទីរទេសចរណ៍ខេត្តកោះកុង យកមកបំពេញបន្ថែមនៅមន្ទីរទេសចរណ៍ រាជធានីភ្នំពេញ វិញ
- បន្ថែមក្របខណ្ឌចំនួន ០៣កន្លែង ដែលនៅសល់ទៅមន្ទីរទេសចរណ៍ ខេត្តតាកែវ
- និយ័តក្របខណ្ឌដែលនៅសល់ ០២កន្លែង ពីមន្ទីរទេសចរណ៍ខេត្តត្បូងឃ្មុំ យកមកបំពេញបន្ថែមនៅមន្ទីរទេសចរណ៍ខេត្ត ក្រចេះ ០១កន្លែង និងមន្ទីរទេសចរណ៍ខេត្តបាត់ដំបង ០១កន្លែង វិញ
- និយ័តក្របខណ្ឌដែលនៅសល់ចំនួន ០២កន្លែង ក្នុងនោះពីមន្ទីរទេសចរណ៍ខេត្តរតនគិរី ០១កន្លែង និងខេត្តមណ្ឌលគិរី ០១កន្លែង យកមកបំពេញបន្ថែមនៅមន្ទីរទេសចរណ៍ខេត្តកំពង់ឆ្នាំង វិញ។

**ប្រការ ២** ៖ បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣** ៖ គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសបេក្ខជន សិស្ស និស្សិតនិងមន្ត្រីរាជការស៊ីវិលឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់និងនេសាទ ក្រសួងទេសចរណ៍ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងនាយកដ្ឋានគ្រប់គ្រងក្របខណ្ឌនៃក្រសួងមុខងារសាធារណៈ ត្រូវសហការអនុវត្តសេចក្តីសម្រេចនេះឱ្យទទួលបានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ពុធ ៣កើត ខែ ធ្នូ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**ចម្លងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

" ដើម្បីជូនជ្រាប "

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

-ក្រសួងធនធានទឹក និងឧតុនិយម

-ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ

-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

-អគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ

" ដើម្បីសហការអនុវត្ត "

-ឯកសារ កាលប្បវត្តិ